# អត្ថបទស្រាវជ្រាវ និង វិភាគ

អត្ថបទដកស្រង់ចេញពីព្រឹត្តិបត្រ ច្បាប់ និងយុត្តិធម៌ លេខ ២
បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌




# ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

រៀបចំដោយ៖

-ឯកឧត្តម **សេង ប៊ុនឃាង** សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-ឯកឧត្តម **ញាន វណ្ណៈ** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងយុត្តិធម៌

ឯករាជ្យភាពនៃអំណាចតុលាការ គឺជាធាតុដ៏សំខាន់មិនអាចខ្វះបាននៅក្នុងសង្គមនីតិរដ្ឋ ស្របតាមគោលការណ៍នៃការបែងចែកអំណាចរវាងអំណាចទាំង ៣ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ជាគោលការណ៍ ឯករាជ្យភាពនៃអំណាចតុលាការនេះ ត្រូវបានធានាដោយប្រមុខរដ្ឋ ដែលអាចជាព្រះមហាក្សត្រ ឬប្រធានាធិបតី អាស្រ័យទៅតាមប្រព័ន្ធនៃការដឹកនាំប្រទេសនីមួយៗ។ សម្រាប់កម្ពុជា យន្តការសម្រាប់ធានាឯករាជ្យភាពនៃអំណាចតុលាការ ត្រូវបានបង្កើតឡើងជាលើកដំបូងដោយរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាឆ្នាំ១៩៤៧ និងមានការវិវត្តជាបន្តបន្ទាប់ទៅតាមរបបនៃការដឹកនាំប្រទេស។ នៅឆ្នាំ១៩៤៧ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យចៅក្រមទាំងឡាយរក្សាវិន័យ និងធានាឥស្សរភាពនៃចៅក្រម។ ការធានាឯករាជ្យភាពនៃអំណាចតុលាការ មិនត្រូវបានកំណត់ជាក់លាក់ថាជាមុខងាររបស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការនោះទេ។ ក្រុមប្រឹក្សានេះត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអធិបតី និងក្រោយមកត្រូវបានកែសម្រួលឱ្យមកស្ថិតនៅក្រោមអធិបតីភាពនៃព្រះមហាក្សត្រវិញ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្លាយជាអនុប្រធាន រួមនិងសមាជិកចំនួន ៦ រូប ដែលក្នុងនោះ ចាត់តាំងដោយព្រះមហាក្សត្រចំនួន ២ រូប, ជ្រើសតាំងដោយរដ្ឋសភាចំនួន ២ រូប និងជ្រើសតាំងដោយចៅក្រមទូទាំងប្រទេសចំនួន ២ រូប[1]។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងទទួលធ្វើជាអធិបតី ក្នុងករណីព្រះមហាក្សត្រមិនមានព្រះរាជវត្តមាន ឬមិនចាត់តាំងសមាជិកឧត្តមក្រុមប្រឹក្សាអមព្រះអង្គធ្វើជាអធិបតីទេ។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការនេះ ត្រូវបានប្តូរទៅជាឧត្តមក្រុមប្រឹក្សាតុលាការ ដោយរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ដែលមានប្រធានាធិបតីនៃសាធារណរដ្ឋជាប្រធាន ហើយក្នុងករណីប្រធានាធិបតីមានធុរៈ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អនុប្រធានាធិបតីនៃសាធារណរដ្ឋ[2]។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ឧត្តមក្រុមប្រឹក្សាតុលាការនេះ ត្រូវបានលុបបំបាត់ចោល។ ក្រោយការរំដោះជាតិពីរបបខ្មែរក្រហម, យន្តការនេះមិនទាន់ត្រូវបានបង្កើតឡើងវិញនោះទេ ទាំងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ទាំងក្នុងរបបរដ្ឋកម្ពុជា ដោយអំណាចទាំងអស់ត្រូវប្រមូលផ្តុំនៅក្រោមក្រុមប្រឹក្សារដ្ឋ។ យន្តការនេះ ទើបត្រូវបានបង្កើតឡើងវិញនៅពេលដែលរបបរាជា

1• មាត្រា១១៤ (មាត្រា៩៦ចាស់) នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៤៧ ដែលត្រូវបានកែប្រែ និងបន្ថែមតាមច្បាប់ដែលរដ្ឋសភាទី៣ បានអនុម័តជាលើកទី២ កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៥៥ ហើយដែលមានព្រះរាជក្រមប្រកាសឱ្យប្រើលេខ ៦៥ ន.ស. ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៦។

2• មាត្រា៨៩ ដល់មាត្រា៩១ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរឆ្នាំ១៩៧២។

និយមអាស្រ័យរដ្ឋធម្មនុញ្ញ ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដោយមានឈ្មោះថ្មីថា **“ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម”**។

ផ្អែកតាមរដ្ឋធម្មនុញ្ញដែលចែងអំពីអំណាចតុលាការ[3] គឺអំណាចតុលាការជាអំណាចឯករាជ្យ។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការបានឡើយ។ ព្រះមហាក្សត្រ ដែលជាព្រះប្រមុខរដ្ឋមួយជីវិត គឺទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដើម្បីជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នកំពូលមួយរបស់ជាតិ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាអធិបតីភាពនៃព្រះមហាក្សត្រ។ សមាសភាព មុខងារ និងការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវកំណត់ក្នុងច្បាប់រៀបចំអង្គការមួយដោយឡែក គឺច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៩ ន.ស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤។ យោងតាមច្បាប់នេះ សមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺមានព្រះមហាក្សត្រជាព្រះប្រធាន និងមានសមាជិក ៨រូប ដែលរួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល, អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, ប្រធានសាលាឧទ្ធរណ៍, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រម ៣រូប ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស។ ក្រោយពីច្បាប់នេះចូលជាធរមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីមានការព្រមព្រៀងពីប្រធានតុលាការកំពូល ត្រូវស្នើសុំទៅព្រះមហាក្សត្រតែងតាំងចៅក្រម ៣រូប ជាសមាជិកបណ្តោះអាសន្នសិន សម្រាប់អំឡុងពេលដែលពុំទាន់អាចរៀបចំការបោះឆ្នោតបាន។ សមាជិកជ្រើសតាំង ៣រូប នេះ មានអាណត្តិ ៥ឆ្នាំ ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយចៅក្រម បន្ទាប់ពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមចូលជាធរមាន។ ប៉ុន្តែ ដោយសារមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ទើបការបោះឆ្នោតជ្រើសតាំងត្រូវអូសបន្លាយរហូតដល់មានច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[4] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មី[5] បានប្រកាសឱ្យប្រើនៅថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤។ ផ្អែកតាម

---

3. អំពី អំណាចតុលាការ (ជំពូកទី១១ថ្មី, មាត្រា១២៨ថ្មី ដល់មាត្រា ១៣៥ថ្មី) នៃរដ្ឋធម្មនុញ្ញ។
4. ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា, ព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
5. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦-០៧-២០១៤

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្មីនេះ តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាសភាពអ្វីខ្លះ? តើសមាសភាពឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានជ្រើសរើសដោយរបៀបណា? តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានមុខងារ ឬសមត្ថកិច្ចអ្វីខ្លះ? និង តើកិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

## ១- សមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ បើប្រៀបធៀបច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឆ្នាំ១៩៩៤ និងឆ្នាំ២០១៤, សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានដំឡើងពី ៨រូប[6] ទៅជា ១១រូប ហើយសមាជិកបម្រុងដែលមានកំណត់ក្នុងច្បាប់ឆ្នាំ១៩៩៤ ត្រូវបានលុបចោល។ ចំពោះសមាជិកទាំង ១១រូប ក្នុងច្បាប់ឆ្នាំ២០១៤ ត្រូវបានចែកចេញជា ២ ប្រភេទ គឺសមាជិកស្វ័យប្រវត្តិដោយផ្អែកលើមុខងារ និងសមាជិកជ្រើសតាំង ដែលរួមមានដូចខាងក្រោម៖

ក-សមាជិកភាពស្វ័យប្រវត្តិដោយផ្អែកលើមុខងារ មាន ៣រូប រួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

ខ-សមាជិកជ្រើសតាំងមាន ៨រូប ដូចខាងក្រោម៖

- ៤រូប ជាសមាជិកជ្រើសតាំងដោយព្រឹទ្ធសភា, ជ្រើសតាំងដោយរដ្ឋសភា, ជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ, និងជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះសមាជិកជ្រើសតាំងដោយព្រឹទ្ធសភា, ជ្រើសតាំងដោយរដ្ឋសភា និងជ្រើសតាំងដោយក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមបេក្ខជនជាឥស្សរជនដែលជាអតីតចៅក្រម ឬព្រះរាជអាជ្ញា ឬឥស្សរជនដែលមានបទពិសោធន៍ការងារយ៉ាងតិច ១៥ឆ្នាំ ឡើងទៅក្នុងវិស័យច្បាប់ ឬតុលាការ។ ចំពោះសមាជិកជ្រើសតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវជ្រើសរើសក្នុងចំណោមព្រះរាជអាជ្ញាពេញសិទ្ធិ។

---

6• ផ្អែកតាមមាត្រា២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឆ្នាំ១៩៩៤, សមាសភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួមមាន ព្រះមហាក្សត្រជាព្រះប្រធាន និងមានសមាជិក ៨រូបទៀត រួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ប្រធានតុលាការកំពូល, អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល, ប្រធានសាលាឧទ្ធរណ៍, អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងចៅក្រម ៣ រូប ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវមានសមាជិកបម្រុង ៣ រូបទៀត ដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រមទូទាំងប្រទេស សម្រាប់ជំនួសសមាជិកជាប់ឆ្នោតដែលអវត្តមាន។

- ៤រូប ជាសមាជិកជ្រើសតាំង តាមរយៈការបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេស ដែលក្នុងនោះ ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមនៃសាលាជម្រះក្តីជាន់ខ្ពស់, ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាបម្រើការងារនៅមហាអយ្យការអមសាលាជម្រះក្តីជាន់ខ្ពស់ និងនៅក្រសួងយុត្តិធម៌, ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយចៅក្រមពេញសិទ្ធិនៃសាលាដំបូងទូទាំងប្រទេស និង ១រូប ជ្រើសតាំងតាមការបោះឆ្នោតដោយព្រះរាជអាជ្ញាពេញសិទ្ធិនៃអយ្យការអមសាលាដំបូងទូទាំងប្រទេស។ ចំពោះបែបបទ និងនីតិវិធីនៃការបោះឆ្នោតជ្រើសតាំងសមាជិកជ្រើសតាំងដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីទទួលបានការឯកភាពពីសមាជិកភាគច្រើននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ បេក្ខជនដែលមានបំណងឈរឈ្មោះ ត្រូវដាក់ពាក្យសុំឈរឈ្មោះដោយផ្ទាល់នៅអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[7]។ ក្រោយពីការបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញាទូទាំងប្រទេសរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈកម្មការរៀបចំការបោះឆ្នោត ប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅពេលរាប់សន្លឹកឆ្នោតរួច និងចុងក្រោយបន្ទាប់ពីផុតរយៈពេលនៃការប្ដឹងតវ៉ាក្នុងរយៈពេល ២៤ ម៉ោង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។ សមាជិកជ្រើសតាំងនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានអាណត្តិ ៥ឆ្នាំ ហើយអាចឈរឈ្មោះជាថ្មីសម្រាប់អាណត្តិបន្តបន្ទាប់ទៀតបានដោយមិនមានកំណត់ចំនួនអាណត្តិនោះទេ។ សមាជិកជ្រើសតាំងនេះ ត្រូវបញ្ចប់នៅពេលសមាជិកជ្រើសតាំងថ្មីត្រូវបានតែងតាំង។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចសម្រេចដកតំណែងសមាជិកជ្រើសតាំងណាម្នាក់បាន ក្នុងករណីដែលសមាជិកជ្រើសតាំងនោះ បានរំលោភបំពានធ្ងន់ធ្ងរលើបទបញ្ញាផ្ទៃក្នុងរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬការធ្វើសកម្មភាពនានាដែលនាំឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ការដកតំណែងនេះ ត្រូវធ្វើឡើងដោយការបោះឆ្នោតសម្រេច ដែលត្រូវមានសម្លេងយល់ព្រមពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមយ៉ាងតិច ៨រូប។ ចំពោះសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ដោយគ្មានការព្យួរទោសពី

---

[7]. បេក្ខជនដែលអាចដាក់ពាក្យសុំឈរឈ្មោះបានគឺជាចៅក្រម-ព្រះរាជអាជ្ញាពេញសិទ្ធិនៃសាលាដំបូង និងអយ្យការអមសាលាដំបូង, សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍, តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល និងនៅក្រសួងយុត្តិធម៌។

បទឧក្រិដ្ឋ ឬពីបទមជ្ឈិមដែលប្រព្រឹត្តដោយចេតនា ត្រូវដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិ។ ចំណែកឯការសម្រេចផ្តន្ទាទោសពីបទមជ្ឈិមដោយអចេតនា មិនមែនជាមូលហេតុនៃការដកចេញពីមុខតំណែងដោយស្វ័យប្រវត្តិនោះទេ។

មុខងារជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី លើកលែងតែប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានវិសមិតភាពមុខងារ ត្រូវស្នើសុំផ្អាច់ពីមុខងារជាចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ដោយអនុវត្តស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[8] និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[9]។

## ២-រចនាសម្ព័ន្ធ និងកិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវដំណើរការប្រជុំក្រោមព្រះរាជាធិបតីភាពរបស់ព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬព្រះរាជតំណាងណាម្នាក់ ដែលទទួលបានការចាត់តាំងដោយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ព្រះរាជតំណាងដែលទទួលបានការចាត់តាំង ដឹកនាំ និងចាត់ចែងការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវរាយការណ៍ឱ្យបានទៀងទាត់អំពីសកម្មភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមថ្វាយព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងតាមការកោះប្រជុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមព្រះរាជបញ្ជានៃព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សមាជិក ៤រូបយ៉ាងតិច អាចស្នើឱ្យមានកិច្ចប្រជុំរបស់ឧត្តមប្រឹក្សានៃអង្គចៅក្រមបាន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវរៀបចំទូលថ្វាយព្រះប្រធាន ស្នើសុំព្រះរាជតម្រិះដើម្បីកោះប្រជុំ។ កិច្ចប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចដំណើរការទៅបានលុះត្រាតែមានសមាជិកចូលរួមប្រជុំចំនួន ៦ រូបយ៉ាងតិច

8· មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

9· មាត្រា ៤៤ និងមាត្រា ៩០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

ហើយការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលយកជាការបាន ត្រូវមានសំឡេងយ៉ាងតិច ៦សំឡេង តាមការបោះឆ្នោតជាសម្ងាត់។ ព្រះប្រធាន ឬព្រះរាជតំណាង មិនចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។ ប៉ុន្តែក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល ត្រូវបានចាត់តាំងជាព្រះរាជតំណាងនោះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រធានតុលាការកំពូល មានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេចចិត្តដូចសមាជិកដទៃទៀតដែរ។

ជាទូទៅ កិច្ចប្រជុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងរៀងរាល់ ៣ខែម្តង ក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។ កិច្ចប្រជុំនេះក៏អាចធ្វើមុនកាលកំណត់បានដែរ តាមរយៈការស្នើសុំរបស់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៤រូបយ៉ាងតិច[10]។ បន្ទាប់ពីទទួលបានព្រះរាជតម្រិះយល់ព្រមពីព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អគ្គលេខាធិការត្រូវរៀបចំរាល់លិខិតអញ្ជើញគ្រប់សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយភ្ជាប់នូវរបៀបវារៈប្រជុំ[11] របាយការណ៍ និងឯកសារផ្សេងៗសម្រាប់ប្រជុំ ឱ្យបានយ៉ាងតិច ១០ថ្ងៃមុនថ្ងៃប្រជុំ ហើយក្នុងករណីបន្ទាន់ រយៈពេលនេះត្រូវបន្ថយមកក្រោម ៥ថ្ងៃ[12]។ ចំពោះសេចក្តីព្រាងរបៀបវារៈត្រូវដាក់ជូនអង្គប្រជុំដើម្បីសុំការអនុម័តតាមមតិភាគច្រើនដោយលើកដៃ ហើយសមាជិកគ្រប់រូបអាចស្នើបន្ថែម ឬបន្ថយរបៀបវារៈបានដែលត្រូវសម្រេចដោយការបោះឆ្នោតជាសម្ងាត់។

មុននឹងមានកិច្ចប្រជុំនីមួយៗដែលទាក់ទងនឹងការផ្លាស់ប្តូរ ឬផ្ទេរភារកិច្ចចៅក្រម ព្រះរាជអាជ្ញា, អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើលិខិតជូនដំណឹងដល់ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងនីមួយៗ ដើម្បីជម្រាបជូនបន្តដល់សាមីខ្លួនដែលដល់វេនអតីតភាពចាប់ពីបួនឆ្នាំឡើង ត្រូវដាក់ពាក្យសុំជ្រើសរើសទីកន្លែងដែលសាមីខ្លួនមានបំណងចង់ទៅបំពេញការងារ[13]។ លុះដល់ពេលបញ្ចប់កិច្ចប្រជុំ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃ

10▪ ប្រការ១ នៃបទបញ្ជាផ្ទៃក្នុង នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។

11▪ ជាទូទៅរបៀបវារៈមានដូចជាៈ របាយការណ៍ស្តីពីសកម្មភាពការងារចន្លោះសម័យប្រជុំ, ពិនិត្យសម្រេចលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ, ពិនិត្យសម្រេចអំពីការតែតាំង ផ្លាស់ប្តូរ ចៅក្រម និងពិគ្រោះយោបល់លើសំណើតែងតាំង ផ្លាស់ប្តូរ ព្រះរាជអាជ្ញា ។ល។

12▪ ប្រការ២ នៃបទបញ្ជាផ្ទៃក្នុង នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។

13 មានបញ្ជីស្ថិតិចំនួនចៅក្រម ព្រះរាជអាជ្ញា នៅតាមអង្គភាពនីមួយៗ ដែលដល់វេននឹងត្រូវផ្លាស់ប្តូរភ្ជាប់ជាមួយ។

អង្គចៅក្រម ចេញសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃសម័យប្រជុំ ដើម្បីជម្រាបជូនដល់អង្គចៅក្រម និងសាធារណជនជ្រាប។

ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ដោយផ្ទាល់។ ប៉ុន្តែ ក្នុងករណីចាំបាច់បន្ទាន់ និងតាមសំណើរបស់សមាជិកចំនួន៦រូប យ៉ាងតិច ការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើឡើងតាមការបោះឆ្នោតជាសម្ងាត់ដោយប្រយោលបាន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះ បន្ទាប់ពីទទួលបានព្រះរាជតម្រិះពីព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងក្របខ័ណ្ឌនៃច្បាប់ឆ្នាំ១៩៩៤, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវជ្រើសរើសចៅក្រមម្នាក់ និងក្រឡាបញ្ជីម្នាក់ ឱ្យទទួលរ៉ាប់រងមុខងារជាលេខាធិការ ដែលមានភារកិច្ចធ្វើរបាយការណ៍ ធ្វើកំណត់ហេតុ រក្សាឯកសារ និងបំពេញកិច្ចការផ្សេងៗទៀត។ ប៉ុន្តែក្នុងក្របខ័ណ្ឌនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ឆ្នាំ ២០១៤ បានបង្កើតឱ្យមានអគ្គលេខាធិការដ្ឋានមួយ ធ្វើជាសេនាធិការសម្រាប់គាំទ្រដល់កិច្ចដំណើរការការងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាពិសេស លើការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក កិច្ចការព័ត៌មានវិទ្យា ការសម្របសម្រួលកិច្ចការចៅក្រម និងព្រះរាជអាជ្ញា និងការទទួលពាក្យបណ្តឹងទាក់ទងនឹងវិន័យចៅក្រម និងព្រះរាជអាជ្ញា។ អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមរដ្ឋបាលកណ្តាលរបស់ក្រសួងយុត្តិធម៌[14]។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាតំណាងឱ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅក្នុងទំនាក់ទំនងជាមួយបុគ្គលឯកជន ឬបុគ្គលសាធារណៈនានា និងមានភារកិច្ចចាត់ចែងកិច្ចការរដ្ឋបាលរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានអគ្គលេខាធិការដ្ឋានជាសេនាធិការ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាអាណាប័កទទួលសិទ្ធិដោយពេញច្បាប់ពីព្រះប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះការងារថវិការបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ រាល់កិច្ចការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាក់ទង

14▪ ផ្អែកតាមមាត្រា ៨ នៃច្បាប់ឆ្នាំ២០១៤, ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវកំណត់ដោយអនុក្រឹត្យ (អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤)។

នឹងការលើកសេចក្តីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវរៀបចំកិច្ចការនេះក្នុងនាមឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

## ៣-សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មាត្រា១៣៤ថ្មី (មាត្រា១១៥ ចាស់) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់ឱ្យមានច្បាប់រៀបចំអង្គការមួយដែលនឹងកំណត់អំពីមុខងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ មាត្រាដដែលនេះក៏បានកំណត់រួចជាស្រេចនូវមុខងារសំខាន់ៗ ២ ដែលមិនអាចខ្វះបានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រាប់ធានាឯករាជ្យភាពនៃអំណាចតុលាការ ដែលរួមមាន មុខងារពាក់ព័ន្ធនឹងការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា និងមុខងារក្នុងការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា។ ផ្អែកតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានមុខងារបន្ថែមសំខាន់ ៣ ទៀត គឺពាក់ព័ន្ធនឹងការផ្តល់មតិពិគ្រោះយោបល់លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ទាក់ទងដល់ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ[15], ការផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រម និងព្រះរាជអាជ្ញាទាំងអស់[16] និងការពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា[17]។

ផ្អែកតាមច្បាប់, សមត្ថកិច្ចទាំងនេះត្រូវបានកំណត់ជា **សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម***(៣-១)* និង **សមត្ថកិច្ចក្នុងមុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា***(៣-២)*។

### ៣-១. សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

សមត្ថកិច្ចទូទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គ្របដណ្តប់លើមុខងារក្នុងការតែងតាំងចៅក្រម និងព្រះរាជអាជ្ញា, មុខងារក្នុងការពិនិត្យ និងសម្រេចលើក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា, មុខងារផ្តល់យោបល់ចំពោះការដំឡើងថ្នាក់ និងការដំឡើងឋានន្តរស័ក្តិឱ្យចៅក្រម និងព្រះរាជអាជ្ញា, និងមុខងារពិគ្រោះមតិលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពាក់ព័ន្ធនឹង

---

15. មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
16. មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។
17. មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ការរៀបចំវិស័យតុលាការ និងការប្រព្រឹត្តទៅនៃវិស័យនេះ។ យោបល់របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នេះ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នេះពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីប្រញាប់ រយៈពេលនេះអាចបន្ថយមកត្រឹម ១០ថ្ងៃ។ ចំពោះមុខងារពាក់ព័ន្ធនឹងការតែងតាំងចៅក្រម, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាអ្នកសម្រេច និងលើកយោបល់ថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះចៅក្រមទាំងអស់។ ដោយឡែក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌ ការដាក់ឱ្យនៅទំនេរ និងការលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ពីសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចកើតមានឡើងបន្ទាប់ពីមានកិច្ចប្រជុំដោយផ្ទាល់ ឬដោយប្រយោលក្នុងករណីបន្ទាន់ចាំបាច់។

អំឡុងពេលចន្លោះសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកមានភារកិច្ចចុះទៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី ក្នុងគោលដៅជួយពង្រឹងដល់អង្គចៅក្រមក្នុងការបំពេញការងារ, អនុវត្តច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ ព្រមទាំងលើកកម្ពស់ដំណើរការល្អនៃរដ្ឋបាល និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម។

## ៣-២.សមត្ថកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យ

មុខការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានកំណត់ជាសមត្ថកិច្ចពិសេសរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ជាគោលការណ៍ច្បាប់ ចៅក្រមមានឯករាជ្យភាពក្នុងការសម្រេចសេចក្តី ប៉ុន្តែការសម្រេចនេះត្រូវឈរលើគោលការណ៍គោរពច្បាប់។ ចៅក្រម និងព្រះរាជអាជ្ញា មិនត្រូវទទួលកំហុសខាងវិន័យចំពោះការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តច្បាប់នោះទេ លើកលែងតែការសម្រេចសេចក្តីនោះធ្វើឡើងដោយរំលោភបំពានក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និង

មុខងាររបស់ខ្លួន។ ចៅក្រម និងព្រះរាជអាជ្ញា មានកាតព្វកិច្ចត្រូវគោរពតាមច្បាប់ និងនីតិវិធីជាធរមានឱ្យបានត្រឹមត្រូវ។ ទន្ទឹមនេះ ចៅក្រម និងព្រះរាជអាជ្ញា ក៏មានកាតព្វកិច្ចក្នុងការគោរពឱ្យបានម៉ឺងម៉ាត់នូវក្រមសីលធម៌ចៅក្រម[18] ដោយមិនត្រូវប្រព្រឹត្តអំពើណាមួយដែលនាំឱ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាពនៃអង្គចៅក្រមឡើយ។ ក្នុងករណីដែលមានការបំពាន, ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចដាក់វិន័យចំពោះចៅក្រម និងព្រះរាជអាជ្ញាណាដែលប្រព្រឹត្តកំហុសនេះ។ ការសម្រេចដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញា ត្រូវធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ ដែលស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូលសម្រាប់មុខការដាក់វិន័យចំពោះចៅក្រម និងក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល សម្រាប់មុខការដាក់វិន័យចំពោះព្រះរាជអាជ្ញា។ ព្រះមហាក្សត្រ ឬព្រះរាជតំណាង ធ្វើជាអធិបតីនៃអង្គប្រជុំក្រុមប្រឹក្សាវិន័យ ដោយមានការចូលរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងករណីសំណុំរឿងវិន័យទាក់ទងនឹងប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។ សេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងការងារវិន័យនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ តើបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញាទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានរបបគតិយុត្តយ៉ាងដូចម្តេច? តើបណ្តឹងនេះនឹងត្រូវចាត់ការរបៀបណាដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម?

## ក- របបគតិយុត្តនៃបណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា

បណ្តឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬនៅក្រសួងយុត្តិធម៌។ នៅពេលទទួលបានពាក្យបណ្តឹង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់ឱ្យពិនិត្យ និងស្រាវជ្រាវជាបឋមលើពាក្យបណ្តឹងទាំងនេះ ដើម្បីកសាងសំណុំរឿងវិន័យ មុននឹងសម្រេចបញ្ជូនសំណុំរឿងនេះទៅក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីចាត់នីតិវិធីបន្ត។

18. ក្រមសីលធម៌ចៅក្រមដែលត្រូវបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ និងឡាយព្រះហស្ថលេខាដាក់ឱ្យប្រើដោយព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧។

ជាគោលការណ៍ បុគ្គលគ្រប់រូបដែលជាភាគីនៃសំណុំរឿងនៅតុលាការ មានសិទ្ធិប្ដឹងទៅឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមអំពីភាពមិនប្រក្រតី ឬកំហុសរបស់ចៅក្រម និងព្រះរាជអាជ្ញានៅក្នុងចំណាត់ការសំណុំរឿង។ បណ្ដឹងនេះធ្វើឡើងដើម្បីទាមទារឱ្យមានការដាក់ទណ្ឌកម្មវិន័យចំពោះចៅក្រម ឬព្រះរាជអាជ្ញាដែលបានប្រព្រឹត្តកំហុសក្នុងការអនុវត្តមុខងាររបស់ខ្លួនជាចៅក្រម ឬជាព្រះរាជអាជ្ញា។ បណ្ដឹងនេះត្រូវធ្វើដោយផ្ទាល់ដោយភាគីនៃសំណុំរឿង ឬដោយមេធាវីតំណាងឱ្យម្ចាស់ភាគីបណ្ដឹង។ ផ្អែកតាមគោលការណ៍នៃការធ្វើបណ្ដឹងទៅតុលាការ, បុគ្គលដែលមិនមានផលប្រយោជន៍ក្នុងការធ្វើបណ្ដឹង មិនមានសិទ្ធិក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ចនោះទេ។ ក្នុងន័យនេះ បុគ្គលផ្សេងក្រៅពីភាគីនៅក្នុងសំណុំរឿងនៅតុលាការ ឬបុគ្គលដែលមិនទទួលបានសិទ្ធិជាតំណាងឱ្យភាគីនៅក្នុងសំណុំរឿងនៅតុលាការ ឬបុគ្គលដែលមិនមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ក៏មិនគួរមានសិទ្ធិដាក់ពាក្យប្ដឹងទៅឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមអំពីកំហុសរបស់ចៅក្រម ឬព្រះរាជអាជ្ញា នៅក្នុងចំណាត់ការសំណុំរឿងជាក់លាក់ណាមួយបាននោះដែរ។ ត្រង់ចំណុចនេះ ច្បាប់មិនបានចែងច្បាស់លាស់នោះទេ។ ប៉ុន្ដែ បើពិនិត្យអំពីក្រមសីលធម៌ចៅក្រម ដែលតម្រូវឱ្យចៅក្រម និងព្រះរាជអាជ្ញា ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវភាពមិនលម្អៀងដើម្បីការពារថែរក្សា និងបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ ពីអ្នកមានវិជ្ជាជីវៈច្បាប់ និងពីភាគីវិវាទនោះ គួរតែទទួលយករាល់បណ្ដឹងអំពីចំណាត់ការមិនប្រក្រតីរបស់ចៅក្រម ឬព្រះរាជអាជ្ញា ដែលប្ដឹងដោយភាគីនៃសំណុំរឿង ឬបណ្ដឹងបរិហារទាំងឡាយណាដែលមានភាពសមហេតុផលបញ្ជាក់ថាចៅក្រម ឬព្រះរាជអាជ្ញាណាមួយ បានប្រព្រឹត្តខុសនឹងកាតព្វកិច្ចវិជ្ជាជីវៈ ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្ដីថ្លៃថ្នូរ ប្រាសចាកពីក្រមសីលធម៌។ ចំពោះការដាក់ពាក្យប្ដឹងអំពីចំណាត់ការមិនប្រក្រតីលើចៅក្រម ឬព្រះរាជអាជ្ញា ហើយទោះបីជាមានការសម្រុះសម្រួលគ្នារវាងភាគីពាក់ព័ន្ធ ឬការដកពាក្យបណ្ដឹងវិញក៏ដោយ ក៏ពាក្យបណ្ដឹងនេះនៅតែត្រូវបានចាត់ការបន្ដដដែល។

តើបណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម អាចធ្វើបាននៅពេលណា? ចំពោះចំណុចនេះ ទោះបីជាច្បាប់មិនបានកំណត់ច្បាស់លាស់ក៏ដោយ, ការប្ដឹងទៅក្រុមប្រឹក្សាវិន័យ គឺមានកម្មវត្ថុទាមទារឱ្យមានការដាក់វិន័យចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលបានប្រព្រឹត្តកំហុសក្នុងចំណាត់ការសំណុំរឿងក្ដី។ ក្នុងន័យនេះ បណ្ដឹងនេះគួរតែអាចទទួលយកបាន លុះត្រា

តែចៅក្រម ឬព្រះរាជអាជ្ញា បានចេញនូវសេចក្ដីសម្រេចណាមួយនៅក្នុងសំណុំរឿងជាមុនសិន។ ហេតុដូចនេះ ដើម្បីធានាបាននូវឯករាជ្យភាពនៃការសម្រេចសេចក្ដីរបស់ចៅក្រម ឬព្រះរាជអាជ្ញា, បើសិនភាគីគ្រាន់តែយល់ថាចៅក្រម ឬព្រះរាជអាជ្ញាណាមួយបានប្រព្រឹត្តកំហុសក្នុងការចាត់ការសំណុំរឿងក្នុងពេលដែលចៅក្រម ឬព្រះរាជអាជ្ញានោះ មិនទាន់បានចេញសេចក្ដីសម្រេចណាមួយនៅឡើយនោះ បណ្ដឹងនេះមិនគួរអាចធ្វើទៅបាននោះទេ។ ម្យ៉ាងទៀត បណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ទៅក្រុមប្រឹក្សាវិន័យមិនមានអានុភាពចំពោះចំណាត់ការសំណុំរឿងនោះទេ។ ដូចនេះ ដើម្បីជៀសវាងការដាក់សម្ពាធលើចៅក្រម ឬព្រះរាជអាជ្ញា ដែលទទួលបន្ទុកសំណុំរឿង, បណ្ដឹងនេះមិនគួរត្រូវបានទទួលយកមកពិនិត្យ និងចាត់ការនោះទេ នៅពេលដែលសំណុំរឿងកំពុងស្ថិតក្នុងចំណាត់ការរបស់ចៅក្រម ឬព្រះរាជអាជ្ញា ដោយពុំទាន់មានចេញសេចក្ដីសម្រេចណាមួយនោះ លើកលែងតែបណ្ដឹងនោះ ប្ដឹងអំពីការមិនគោរពក្រមសីលធម៌ ដែលមិនពាក់ព័ន្ធនឹងសេចក្ដីសម្រេចក្នុងចំណាត់ការសំណុំរឿង ដូចជា ចៅក្រម ឬព្រះរាជអាជ្ញា បានបង្ហាញអំពីភាពលម្អៀងក្នុងចំណាត់ការសំណុំរឿង ឬមានអាកប្បកិរិយាមិនសមរម្យជាមួយភាគីនៃសំណុំរឿងជាដើម។

ម្យ៉ាងវិញទៀត តើបទប្បញ្ញត្តិគតិយុត្តជាធរមាន បានកំណត់អំពីអាជ្ញាយុកាលសម្រាប់ការដាក់ពាក្យបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា ដែរឬទេ? អាជ្ញាយុកាលនៃបណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏មិនបានកំណត់ក្នុងច្បាប់ជាធរមាននោះដែរ។ តើគួរមានការកំណត់អំពីអាជ្ញាយុកាលនៃបណ្ដឹងនេះដែរឬទេ ស្របពេលដែលអាជ្ញាយុកាលនៃបណ្ដឹងទៅតុលាការ ត្រូវបានកំណត់ទាំងសំណុំរឿងរដ្ឋប្បវេណី ទាំងសំណុំរឿងព្រហ្មទណ្ឌ? លើសពីនេះ បើពិនិត្យមើលក្នុងសំណុំរឿងរដ្ឋប្បវេណី ជាពិសេសផ្អែកតាមមាត្រា៣១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគីអាចធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលដែលសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរ ឬគិតចាប់ពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយពេលសេចក្ដីសម្រេចរបស់តុលាការបានចូលជាស្ថាពរ។ ហេតុដូចនេះ តើគួរទទួលយកបណ្ដឹងអំពីវិន័យទាក់ទងនឹងចៅក្រម និងព្រះរាជអាជ្ញា មកពិនិត្យទៀតដែរឬទេ នៅពេលដែលសេចក្ដីសម្រេចរបស់តុលាការ

បានចូលជាស្ថាពរ ហើយភាគីលែងមានសិទ្ធិប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើងវិញហើយ? ឈរលើមូលដ្ឋាននៃអាជ្ញាយុកាលទាំងនៅក្នុងសំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ, បណ្ដឹងទៅក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក៏គួរត្រូវបានគិតគូរពិចារណាផងដែរ។

## ខ- ចំណាត់ការរបស់ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងមុខការដាក់វិន័យ

ដូចបានគូសបញ្ជាក់ពីខាងលើ ការសម្រេចដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ត្រូវធ្វើឡើងដោយឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រោមរូបភាពជាក្រុមប្រឹក្សាវិន័យ។ ក្រុមអធិការកិច្ចនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើងដើម្បីជួយក្រុមប្រឹក្សាវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការស៊ើបអង្កេត និងស្រាវជ្រាវសំណុំរឿងវិន័យ។

រាល់ពាក្យបណ្ដឹងវិន័យទាំងអស់ ដែលពាក់ព័ន្ធនឹងកំហុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ ឬប្រាសចាកក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់នៅអគ្គលេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ឬក្រសួងយុត្តិធម៌។ បន្ទាប់ពីទទួលបានសំណុំរឿងវិន័យ ប្រធានក្រុមប្រឹក្សាវិន័យអាចចាត់ឱ្យក្រុមអធិការកិច្ចធ្វើការស៊ើបអង្កេត និងស្រាវជ្រាវ ឬធ្វើការពិនិត្យវាយតម្លៃ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន។ ក្រុមអធិការកិច្ចក្នុងក្របខ័ណ្ឌបំពេញការងាររបស់ខ្លួន ដោយមានការចាត់តាំងពីប្រធានក្រុមប្រឹក្សាវិន័យ អាចស្នើសុំពិនិត្យសំណុំរឿងនានាដែលពាក់ព័ន្ធ ឬមានប្រយោជន៍ដល់សំណុំរឿងវិន័យ ហើយក្នុងករណីចាំបាច់អាចស្នើសុំការបំភ្លឺពីគ្រប់បុគ្គលនានាបាន។ ចៅក្រម ឬព្រះរាជអាជ្ញា ដែលមិនផ្ដល់កិច្ចសហការតាមការស្នើសុំរបស់ក្រុមអធិការកិច្ច ត្រូវចាត់ទុកជាកំហុសវិន័យ[19]។ ចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលកំពុងជាប់នៅក្នុងនីតិវិធីវិន័យ ប្រធានក្រុមប្រឹក្សាវិន័យ អាចសម្រេចផ្អាកពីមុខងារបណ្ដោះអាសន្នមួយរយៈសិន[20]។

បន្ទាប់ពីស៊ើបអង្កេតចប់ ក្រុមអធិការកិច្ចត្រូវធ្វើរបាយការណ៍ដាក់ជូនប្រធានក្រុមប្រឹក្សាវិន័យដើម្បីចាត់ការបន្ត។ របាយការណ៍របស់ក្រុមអធិការកិច្ច មិនមែនជាចំណងដល់ប្រធាន

---

19• មាត្រា ២២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។

20• មាត្រា ៥៤ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

ក្រុមប្រឹក្សាវិន័យដើម្បីសម្រេចលើសំណុំរឿងវិន័យនោះទេ។ បើយល់ឃើញថាគ្មានកំហុសខាងវិន័យ ប្រធានក្រុមប្រឹក្សាវិន័យអាចសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការបាន។ ប៉ុន្តែ ក្នុងករណីសំណុំរឿងវិន័យត្រូវបានសម្រេចបញ្ជូនទៅក្រុមប្រឹក្សាវិន័យនោះ ប្រធានក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ថ្ងៃប្រជុំក្រុមប្រឹក្សាវិន័យ ហើយអគ្គលេខាធិការត្រូវរៀបចំរាល់សំណុំរឿងវិន័យ និងឯកសារពាក់ព័ន្ធដើម្បីផ្ញើជូនគ្រប់សមាជិកទាំងអស់ និងចៅក្រមរបាយការណ៍ ឬព្រះរាជអាជ្ញារបាយការណ៍ និងសាមីខ្លួន យ៉ាងតិច ១០ថ្ងៃ មុនថ្ងៃប្រជុំ។ សាមីខ្លួនជាចៅក្រម ឬព្រះរាជអាជ្ញាដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿងវិន័យត្រូវបានជូនដំណឹងឱ្យដឹងអំពីពាក្យបណ្តឹងដែលចោទប្រកាន់លើខ្លួន និងមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬដោយមានជំនួយពីមេធាវី នៅចំពោះមុខអង្គប្រជុំក្រុមប្រឹក្សាវិន័យ។

ការប្រជុំរបស់ក្រុមប្រឹក្សាវិន័យ ត្រូវធ្វើជាអសាធារណៈ ហើយសមាជិកនៃអង្គប្រជុំទាំងអស់ត្រូវរក្សាការសម្ងាត់នៃអង្គប្រជុំ។ ក្នុងនីតិវិធីដំបូងនៃកិច្ចប្រជុំក្រុមប្រឹក្សាវិន័យ ប្រធានក្រុមប្រឹក្សាវិន័យចាត់ឱ្យចៅក្រមរបាយការណ៍ ឬព្រះរាជអាជ្ញារបាយការណ៍ អានរបាយការណ៍នៃសំណុំរឿងវិន័យដែលខ្លួនបានស៊ើបអង្កេត និងស្រាវជ្រាវ ជូនអង្គប្រជុំ។ បន្ទាប់ពីបញ្ចប់កិច្ចសួរដេញដោល ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដំណើរការពិភាក្សាដើម្បីសម្រេច។ ចំពោះនីតិវិធីនៃការសម្រេច គឺមានបែងចែកជាពីរដំណាក់កាល ដែលដំណាក់កាលទី១ គឺត្រូវពិនិត្យសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃកំហុស និងបើសិនជាសម្រេចថាមានកំហុសហើយទើបឈានចូលដំណាក់កាលទី២ ដែលត្រូវសម្រេចអំពីទណ្ឌកម្ម។

- **ដំណាក់កាលទី១៖** ប្រធាន និងសមាជិកក្រុមប្រឹក្សាវិន័យទាំងអស់បោះឆ្នោតសម្រេចថាចៅក្រម ឬព្រះរាជអាជ្ញា ដែលពាក់ព័ន្ធសំណុំរឿងវិន័យ មានកំហុស ឬគ្មានកំហុស។ ក្នុងករណីការបោះឆ្នោតទទួលបានការសម្រេចថាគ្មានកំហុសនោះ សំណុំរឿងវិន័យនេះត្រូវបានបិទបញ្ចប់។
- **ដំណាក់កាលទី២៖** ក្នុងករណីការបោះឆ្នោតក្នុងដំណាក់កាលទី១ ទទួលបានការសម្រេចថាមានកំហុសនោះ ត្រូវធ្វើការបោះឆ្នោតសម្រេចអំពីកម្រិត និងប្រភេទនៃទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

កូរ៉ុមប្រជុំ និងការសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវអនុវត្តដូចគ្នានឹងកូរ៉ុមប្រជុំ និងការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែរ។

កំហុសវិន័យដែលត្រូវដាក់លើចៅក្រម ឬព្រះរាជអាជ្ញា មានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា[21]។ សេចក្តីសម្រេចដាក់វិន័យ ត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យនេះ ត្រូវដាក់ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីពិនិត្យ និង សម្រេច ហើយសេចក្តីសម្រេចចុងក្រោយនេះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

ក្នុងករណីដែលទណ្ឌកម្មវិន័យថ្នាក់ទី២ ត្រូវបានប្រកាស ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីកិច្ចការនេះដើម្បីចេញព្រះរាជក្រឹត្យដាក់វិន័យ។ ចំពោះទណ្ឌកម្មថ្នាក់ទី២ នេះរួមមាន *ការផ្លាស់ដោយបង្ខំ អាចតម្រូវឱ្យទទួលការបណ្តុះបណ្តាលបន្ថែម, ការព្យួរពីការងារមិនឱ្យមានបៀវត្ស ក្នុងរយៈពេលមិនឱ្យលើសពី១ឆ្នាំ, ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរស័ក្តិ, ការដាក់ឱ្យចូលនិវត្តន៍ដោយបង្ខំ, ការបញ្ឈប់ពីមុខងារដោយបង្ខំ និងការបណ្តេញចេញពីក្របខ័ណ្ឌ*។ទណ្ឌកម្មថ្នាក់ទី២ នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ក្នុងករណីពិសេស ប្រសិនបើបណ្តឹងពាក់ព័ន្ធនឹងប្រធានតុលាការកំពូល គឺអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលជាអ្នកចាត់ឱ្យស្រាវជ្រាវ និងស៊ើបអង្កេតដោយប្រើយន្តការក្រុមអធិការកិច្ច ដើម្បីធ្វើរបាយការណ៍លើពាក្យបណ្តឹងនេះ។ ដូចគ្នាផងដែរ ប្រសិនបើបណ្តឹងពាក់ព័ន្ធនឹងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះ គឺប្រធានតុលាការកំពូលជាអ្នកចាត់ឱ្យស្រាវជ្រាវ និងស៊ើបអង្កេតដោយប្រើយន្តការក្រុមអធិការកិច្ច ដើម្បីធ្វើរបាយការណ៍លើពាក្យបណ្តឹងនេះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាវិន័យត្រូវប្រជុំក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ឬព្រះរាជតំណាង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចូលរួមក្នុងអង្គប្រជុំនេះ ហើយកូរ៉ុមប្រជុំត្រូវមាន ៨រូប យ៉ាងតិច។ ចំពោះការសម្រេចត្រូវយកតាមមតិភាគច្រើន។

ចំពោះចៅក្រម ឬព្រះរាជអាជ្ញា ដែលបច្ចុប្បន្នជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយមានបណ្តឹងទាក់ទងនឹងខ្លួន មានសិទ្ធិចូលការពារខ្លួន ប៉ុន្តែ ត្រូវដកខ្លួនចេញនៅពេលពិភាក្សា

21. ទណ្ឌកម្មវិន័យមាន ២ថ្នាក់គឺ ទណ្ឌកម្មថ្នាក់ទី១ និងទណ្ឌកម្មថ្នាក់ទី២ ដូចមានចែងក្នុងមាត្រា ៥៥ និងមាត្រា ៩៩ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

និងសម្រេច មានន័យថា មិនអាចចូលរួមប្រជុំក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឡើយ។

ជាទូទៅពាក្យបណ្តឹងតែងតែប្តឹងចំឈ្មោះទៅអ្នកចាត់ការលើសំណុំរឿងដោយផ្ទាល់ ជាពិសេសក្នុងករណីព្រះរាជអាជ្ញារងណាម្នាក់ចាត់ការសំណុំរឿងហើយត្រូវគេប្តឹងអំពីវិន័យ តើក្រុមប្រឹក្សាវិន័យពិនិត្យ និងសម្រេចលើព្រះរាជអាជ្ញារងនោះតែម្នាក់ឬយ៉ាងណា? បើពិនិត្យទៅលើច្បាប់ ព្រះរាជអាជ្ញាមានអំណាចទៅលើព្រះរាជអាជ្ញារងដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន[22]។ ដូច្នេះ ក្នុងករណីមានបណ្តឹងលើព្រះរាជអាជ្ញារងណាម្នាក់ តើគួរអញ្ជើញព្រះរាជអាជ្ញាដែលជាថ្នាក់លើរបស់ព្រះរាជអាជ្ញារងនោះមកបំភ្លឺចំពោះមុខក្រុមប្រឹក្សាវិន័យដែរឬទេ? បើរកឃើញថាព្រះរាជអាជ្ញាមានកំហុសដូចព្រះរាជអាជ្ញារងដែរ តើព្រះរាជអាជ្ញាត្រូវទទួលទណ្ឌកម្មវិន័យដែរឬទេ? ជាមួយគ្នានេះដែរ ក្នុងករណីសេចក្តីសម្រេចចេញដោយក្រុមប្រឹក្សាជំនុំជម្រះដែលជាទូទៅក្រុមប្រឹក្សាជំនុំជម្រះអាចមានចៅក្រមចំនួន ៣រូប, ៥រូប ឬ ៩រូប តាមករណីជាក់ស្តែងនីមួយៗ។ បើក្នុងករណីក្នុងសេចក្តីសម្រេចនោះត្រូវបានគេប្តឹងអំពីកំហុសវិន័យ ហើយក្រុមប្រឹក្សាវិន័យបានរកឃើញថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនោះបានប្រព្រឹត្តកំហុសវិន័យមែន។ ប៉ុន្តែ នៅក្នុងការសម្រេចសេចក្តីនោះ មានចៅក្រមប្រឹក្សាម្នាក់បានអះអាងថាខ្លួនមិនបានចូលរួមប្រព្រឹត្តកំហុសនោះទេ និងបានបង្ហាញភស្តុតាងច្បាស់លាស់ដែលអាចជឿជាក់បាន។ តើចៅក្រមប្រឹក្សាម្នាក់នោះ គួរត្រូវទទួលទណ្ឌកម្មវិន័យដូចគ្នាដែរឬទេ?

ជាគោលការណ៍ សេចក្តីសម្រេចអំពីវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំពោះចៅក្រម ឬព្រះរាជអាជ្ញាណាម្នាក់ មិនអាចត្រូវបានប្រកាសផ្សព្វផ្សាយជាសាធារណៈ ដោយមានបញ្ជាក់ឈ្មោះចៅក្រម ឬព្រះរាជអាជ្ញាទេ។ ប៉ុន្តែ ដើម្បីផលប្រយោជន៍នៃការទទួលព័ត៌មានសម្រាប់សាធារណជន ការផ្សព្វផ្សាយនេះគួរតែផ្សព្វផ្សាយត្រឹមអង្គហេតុនៃបណ្តឹង សំអាងហេតុ និងការសម្រេចតែប៉ុណ្ណោះ ដោយមិនគួរបង្ហាញអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធទាំងអស់នោះទេ។

---

22. មាត្រា ៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។